ក្រសួងអភិវឌ្ឍន៍លំនៅដ្ឋាន និងទីក្រុងសហរដ្ឋអាមេរិក

# ផ្នែក 8៖ ប័ណ្ណធានាធ្វើឱ្យប្រសើរឡើង



## យល់ដឹងអំពីសិទ្ធិរបស់លោកអ្នក

- លោកអ្នកនៅតែមានសិទ្ធិស្នាក់នៅទីបរិវេណរបស់អ្នក ដោយមានប័ណ្ណធានាធ្វើឱ្យប្រសើរឡើង
- លោកអ្នកអាចស្នាក់នៅ ដរាបណាលំនៅដ្ឋាននានាត្រូវបានប្រើសម្រាប់លំនៅដ្ឋានជួល និងមានសិទ្ធិទទួលស្របច្បាប់ចំពោះជំនួយក្រោមកម្មវិធីលិខិតធានាជម្រើសលំនៅដ្ឋាន
- កិច្ចសន្យាជួលរបស់អ្នកមិនអាចបញ្ចប់ឡើយ លើកលែងមានការរំលោភបំពានលើកិច្ចសន្យាជួលធ្ងន់ធ្ងរ ឬ ហេតុផលល្អៗផ្សេងទៀត

## តើនឹងមានបញ្ហាអ្វីកើតឡើងចំពោះ**លំនៅដ្ឋាន**របស់ខ្ញុំ?

### សកម្មភាពនៃការផ្លាស់ប្តូរ

អគាររបស់អ្នក នឹងអាចមាន ការផ្លាស់ប្តូរ។ ជាទូទៅការណ៍នេះ កើតឡើងនៅពេលមានស្ថានភាពមួយក្នុងចំណោមស្ថានភាពចំនួនបី
កើតឡើង៖ ម្ចាស់អចលនទ្រព្យឯកជនជ្រើសរើសមិនចូលរួមក្នុងកម្មវិធីជំនួយជួលលំនៅដ្ឋាននៅចុងបញ្ចប់នរយៈពេលកិច្ចសន្យានេះ; HUD បញ្ចប់កិច្ចសន្យាជំនួយជួលលំនៅដ្ឋាន; ឬម្ចាស់លំនៅដ្ឋានបង់ផ្តាច់ប្រាក់ឱ្យខ្ចីដោយមានវត្ថុបញ្ចាំដែលជាជំនួយរបស់រដ្ឋាភិបាលជាក់លាក់ មុនពេលកាលបរិច្ឆេទដល់កំណត់ប្រាក់កម្ចីទិញផ្ទះ។ ក្នុងករណីមួយចំនួន ម្ចាស់លំនៅដ្ឋានត្រូវផ្តល់ជូនសេចក្តីជូនដំណឹងដល់លោកអ្នក អំពីបញ្ហានេះដែលមានយៈពេលមួយឆ្នាំ មុនការបញ្ចប់កិច្ចសន្យា។
សកម្មភាពនៃការផ្លាស់ប្តូរនេះ អាចបង្កើតឱ្យមាន

 ដែលក្រុមគ្រួសាររស់នៅក្នុងគម្រោងនេះ អាចនឹងជួបបញ្ហាការកើនឡើងនៃការជួលលំនៅដ្ឋាន។ ដើម្បីការពារលោកអ្នក និងក្រុមគ្រួសារ ពីការកើនឡើងការជួលលំនៅដ្ឋាននោះ ច្បាប់នេះផ្តល់ជូនការការពារអ្នកជួលលំនៅដ្ឋានជាក់លាក់។ ការការពារទាំងនេះ រួមបញ្ចូលទាំងសក្តានុពលចំពោះការផ្តល់ជំនួយជួលលំនៅដ្ឋាន ដែលមានសិទ្ធិស្នាក់នៅបរិវេណលំនៅដ្ឋាន។ ក្រុមគ្រួសាបានកំណត់សិទ្ធិទទួលបាន តាមរយៈអាជ្ញាធរលំនៅដ្ឋានរដ្ឋនៅមូលដ្ឋាន (PHA) ដែលផ្តល់ជូនឱកាសទទួលបានជំនួយជួល
លំនៅដ្ឋាន។ ជំនួយនេះ ត្រូវបានផ្តល់ជូនទាំងប័ណ្ណធានាធ្វើឱ្យប្រសើរឡើង (ការស្នាក់នៅ) ឬប័ណ្ណធានាជម្រើសលំនៅដ្ឋាន (ការផ្លាស់ប្តូរលំនៅដ្ឋាន) ។

## តើអ្វីទៅជាប័ណ្ណធានាធ្វើឱ្យប្រសើរឡើង?

វិធីមួយក្នុងចំណោមវិធីនានាដែល ក្រុមគ្រួសារត្រូវបានផ្តល់ជូនឱកាស ដើម្បីស្នាក់នៅទីបរិវេណលំនៅដ្ឋាន ដោយមានប័ណ្ណធានាធ្វើឱ្យប្រសើរឡើង។ PHA ដែលគ្រប់គ្រងប័ណ្ណធានាទាំងឡាយ នឹងកំណត់សិទ្ធិរបស់អ្នក ដើម្បីទទួលបានប័ណ្ណធានាធ្វើឱ្យប្រសើរឡើង។ ប័ណ្ណធានាទាំងនេះ ខុសគ្នាទៅនឹងប័ណ្ណធានាជម្រើសលំនៅដ្ឋាននៅក្នុងផ្នែក 8 ធម្មតា តាមវិធីពីរយ៉ាង៖

- ទីមួយ ប័ណ្ណធានាធ្វើឱ្យប្រសើរឡើងអនុញ្ញាតឱ្យមានអ្នកមានសិទ្ធិស្នាក់នៅក្នុងទីបរិវេណលំនៅដ្ឋាន បន្ទាប់ពីសកម្មភាពនៃការផ្លាស់ប្តូរ ដរាបណាលំនៅដ្ឋាន
បន្តដំណើរការប្រើប្រាស់ជាលំនៅដ្ឋានជួល។
- ទីពីរ ចំនួនទឹកប្រាក់ដែល PHA អាចបង់សម្រាប់ការជួលនៅក្នុងទីបរិវេណលំនៅដ្ឋាននេះ អាចមានចំនួនទឹកប្រាក់ច្រើនជាង PHA នឹងអាចបង់សម្រាប់លំនៅដ្ឋានដែលស្រដៀងគ្នា ដោយមានប័ណ្ណធានាជម្រើសលំនៅដ្ឋានធម្មតា។

សូមចងចាំថា *លោកអ្នកអាចស្នាក់នៅបរិវេណអគារ។* លោកអ្នកមិនអាចត្រូវបានគេប្រាប់ឱ្យចាកចេញ ឬបណ្តេញចេញឡើយ លើកលែងតែមានការរំលោភបំពានលើ
កិច្ចសន្យាជួលលំនៅដ្ឋាន ធ្ងន់ធ្ងរ ឬម្តងហើយម្តងទៀត។ ការរំលោភបំពានទាំងនេះ គឺជាអ្វីដែលមាន ដូចជាការមិនបានបង់ប្រាក់ជួលរបស់អ្នក, ការដែលមិនថែរក្សាលំនៅដ្ឋាន
និងការរំលោភ កិច្ចសន្យាជួលលំនៅដ្ឋានផ្សេងទៀត ដែលបានរៀបរាប់នៅក្នុងកិច្ចសន្យាដែលលោកអ្នកបានចុះហត្ថលេខា។ លោកអ្នកនៅតែមានសិទ្ធិក្នុងការប្តឹងទៅកាន់តុលាការចំពោះកិច្ចដំណើរការនីតិវិធីបណ្តេញចេញ។ ដោយផ្អែកលើតម្រូវការរបស់ HUD, ប្រសិនបើលោកអ្នកកំពុងតែរស់នៅក្នុងលំនៅដ្ឋានមួយ ដែល PHA កំណត់ថា មានទំហំធំពេក ឬតូចពេកសម្រាប់ក្រុមគ្រួសាររបស់អ្នក នោះលោកអ្នកអាចត្រូវបានគេស្នើសុំឱ្យផ្លាស់ប្តូរលំនៅដ្ឋានទៅកាន់លំនៅដ្ឋានដែលមានទំហំសមរម្យសម្រាប់គ្រួសាររបស់លោកអ្នក។

Khmer Cambodian

ក្រសួងអភិវឌ្ឍន៍លំនៅដ្ឋាន និងទីក្រុងសហរដ្ឋអាមេរិក

# ផ្នែក 8៖ ប័ណ្ណធានាធ្វើឱ្យប្រសើរឡើង

### ឧទាហរណ៍ការរំលោភបំពានលើកិច្ចសន្យាជួលធ្ងន់ធ្ងរ

- ការខកខានចំពោះការបង់ថ្លៃជួល
- ហេតុផលល្អៗ ដែលស្ថិតក្រោមកម្មវិធីប័ណ្ណធានាលំនៅដ្ឋាន
- ការខកខានថែទាំលំនៅដ្ឋាន
- ប្រព្រឹត្តឧក្រិដ្ឋកម្មហិង្សានៅលំនៅដ្ឋាន
- អ្វីៗដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាជួលលំនៅដ្ឋាននេះ ជាហេតុផលដែលអនុញ្ញាតឱ្យមានការបញ្ចប់សិទ្ធិជួល

## ខ្ញុំចង់ស្វែងរកកន្លែងថ្មីមួយ ដើម្បីរស់នៅ

### សិទ្ធិផ្លាស់ប្តូរកន្លែងរស់នៅដោយមានលិខិតធានាជម្រើសលំនៅដ្ឋាន

ប្រសិនបើលោកអ្នកមិនចង់ស្នាក់នៅ លំនៅដ្ឋានទេ លោកអ្នកអាចផ្លាស់ប្តូរលំនៅដ្ឋានបាន។ លោកអ្នកនឹងទទួលបានប័ណ្ណធានាជម្រើសលំនៅដ្ឋាន ដើម្បីផ្លាស់ប្តូរលំនៅដ្ឋានដោយជំនួសឱ្យប័ណ្ណធានាធ្វើឱ្យប្រសើរឡើង។ ប្រសិនបើលោកអ្នកសម្រេចចិត្តទទួលប័ណ្ណធានាជម្រើសលំនៅដ្ឋាននោះ លោកអ្នកត្រូវបានគេទាមទារឱ្យបង់ប្រាក់រហូតដល់ទៅ 40% ភាគរយនៃប្រាក់ចំណូលប្រចាំខែដែលបាន
កែតម្រូវរបស់លោកអ្នក។ ប័ណ្ណធានានេះ អនុញ្ញាតឱ្យលោកអ្នករស់នៅកន្លែងណាមួយ ដែលលោកអ្នកចង់ទៅនៅក្នុងប្រទេសនេះ ដរាបណាលោកអ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ដែលបានកំណត់ដោយអាជ្ញាធរលំនៅដ្ឋានរដ្ឋ។ លោកអ្នកអាចស្នើសុំប័ណ្ណធានាផងដែរ ដើម្បីផ្លាស់ប្តូរលំនៅដ្ឋាន មុនពេលការបញ្ចប់រយៈពេលកិច្ចសន្យាជួលណាមួយ។

## ព័ត៌មាន & ជំនួយបន្ថែម

សូមទាក់ទងមកអ្នកតំណាងអាជ្ញាធរលំនៅដ្ឋានរដ្ឋនៅមូលដ្ឋានរបស់អ្នក សម្រាប់ព័ត៌មានជាក់លាក់អំពីការការពារផ្ទះ និងម្ចាស់ផ្ទះរបស់អ្នក។

លោកអ្នកក៏អាចទាក់ទងមកការិយាល័យលំនៅដ្ឋានសមរម្យ និងឱកាសស្មើគ្នានៃ HUD ផងដែរ តាមលេខទូរស័ព្ទ **1-800- 669-9777**, ប្រសិនបើលោកអ្នកមានជំនឿថា លោកអ្នកត្រូវបានគេរើសអើង។





Khmer Cambodian